**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧ ១៣-០១៦ - ៣៣៩ ត.ដ.ពា

# សេចក្តីជូនដំណឹង ស្តីពី
# ការរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ២០១៦ និងការទទួលយកសំណើស្រាវជ្រាវ

## សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ លើកទី៣ របស់ធនាគារជាតិនៃកម្ពុជា ស្តីពី
## វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ៖ កាលានុវត្តភាព និង ហានិភ័យ

វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបានចាប់ផ្តើមមានសកម្មភាពនៅក្នុងអំឡុងដើមទសវត្សរ៍ទី៩០ ហើយបានរីកចម្រើនយ៉ាងឆាប់រហ័ស ព្រមទាំងត្រូវបានទទួលស្គាល់ដោយមតិជាតិនិងអន្តរជាតិថាបានរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា និងគាំទ្រកំណើនសេដ្ឋកិច្ចជាតិ ។ ដំបូងឡើយវិស័យនេះបានកកើតឡើងក្នុងរូបភាពជាអង្គការក្រៅរដ្ឋាភិបាល ដែលបានដើរតួនាទីជាប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដើម្បីអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារនៅតាមមូលដ្ឋាន ។ បន្ទាប់ពីការអនុម័តច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅឆ្នាំ១៩៩៩ វិស័យមីក្រូហិរញ្ញវត្ថុត្រូវបានអភិវឌ្ឍជាលំដាប់ផ្អែកលើយន្តការទីផ្សារ ។ បច្ចុប្បន្ន ទ្រព្យសកម្មវិស័យមីក្រូហិរញ្ញវត្ថុបានកើនដល់ប្រមាណ ១៤.៦២៦ ប៊ីលានរៀល គឺស្មើនឹង ១៨% នៃទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានធនាគារ និងកំពុងផ្តល់ឥណទានដល់ប្រជាជនប្រមាណ ២,២ លាន នាក់ ព្រមទាំងបានផ្តល់សេវាសន្សំដល់ប្រជាជនប្រមាណ ១,៥ លាន នាក់ ។ កាលពីពេលថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាក៏បានប្រារព្ធសន្និសីទជាតិមីក្រូហិរញ្ញវត្ថុលើកទី២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអបអរសាទរការរីកចម្រើនវិស័យមីក្រូហិរញ្ញវត្ថុក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ ។

ទន្ទឹមនឹងការរីកចម្រើននិងការទទួលបានជោគជ័យក្នុងរយៈពេលជាង ២ទសវត្សរ៍កន្លងមកនេះ វិស័យមីក្រូហិរញ្ញវត្ថុក៏បានប្រឈមនឹងការកើនឡើងនៃហានិភ័យផងដែរ ដោយសារទំហំនិងបណ្តាញវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងជាលំដាប់ ស្របតាមវឌ្ឍនភាពនៃសេដ្ឋកិច្ចកម្ពុជា ។ ដើម្បីគ្រប់គ្រងហានិភ័យ និងគាំទ្រការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានពង្រឹងជាប្រចាំលើក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ ព្រមទាំងការត្រួតពិនិត្យលើវិស័យនេះ ។ ការបន្តរក្សាបាននូវស្ថិរភាពនៃការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុមានសារៈសំខាន់ណាស់ក្នុងការរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ និងការគាំទ្រការរីកចម្រើនសកម្មភាពសេដ្ឋកិច្ចនានា ជាពិសេសចំពោះសហគ្រាសធុនតូចនិងមធ្យម និងប្រជាជនក្រីក្រ ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ដើម្បីទទួលបានធាតុចូលបន្ថែមឲ្យបានគ្រប់ជ្រុងជ្រោយពីមជ្ឈដ្ឋានស្រាវជ្រាវក្នុងការបន្តពង្រឹងស្ថិរភាព និងការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុឲ្យនៅតែបន្តមានភាពរឹងមាំនិងប្រកបដោយចីរភាព ធនាគារជាតិនៃកម្ពុជាបានកំណត់យកប្រធានបទសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ ២០១៦ ស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា៖ កាលានុវត្តភាព និង ហានិភ័យ" ដែលគ្រោងនឹងប្រារព្ធឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ ខាងមុខ ។

ធនាគារជាតិនៃកម្ពុជាមានសេចក្តីសោមនស្សរីករាយ សូមអញ្ជើញអ្នកជំនាញ សេដ្ឋវិទូ និងអ្នកស្រាវជ្រាវដើម្បីធ្វើការស្រាវជ្រាវជុំវិញប្រធានបទគោលខាងលើនេះ ។ បេក្ខជនដែលមានចំណាប់អារម្មណ៍សូមផ្ញើសំណើស្រាវជ្រាវ (Research Proposal) ភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេប (CV) មកកាន់អគ្គនាយកដ្ឋានបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជាឲ្យបានមុនថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ។ សូមបញ្ជាក់ថាធនាគារជាតិនៃកម្ពុជានឹងជ្រើសរើសយកសំណើស្រាវជ្រាវចំនួន ៤ ឬ ៥ ឲ្យធ្វើការស្រាវជ្រាវបន្ត ដែលនឹងប្រកាសជូននៅថ្ងៃសុក្រ ទី១៣ ខែឧសភា ឆ្នាំ២០១៦ ។ ក្នុងចំណោមអត្ថបទស្រាវជ្រាវទាំងនេះ អត្ថបទដែលមានគុណភាពសមស្រប នឹងត្រូវអនុញ្ញាតឲ្យធ្វើបទបង្ហាញនៅក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៣ ។ ដើម្បីជាការលើកទឹកចិត្តដល់ជ័យលាភីលើការស្រាវជ្រាវនេះ ធនាគារជាតិនៃកម្ពុជានឹងផ្តល់រង្វាន់ជូនម្ចាស់អត្ថបទស្រាវជ្រាវហើយអត្ថបទស្រាវជ្រាវទាំងនេះនឹងត្រូវចុះផ្សាយលើគេហទំព័រ និងព្រឹត្តិប័ត្រប្រចាំត្រីមាសរបស់ធនាគារជាតិនៃកម្ពុជា ។

*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦*

**អគ្គនាយកបច្ចេកទេស**

**ជា សិរី**

**សូមទំនាក់ទំនងមក**
**ធនាគារជាតិនៃកម្ពុជា**
**អគ្គនាយកដ្ឋានបច្ចេកទេស**
**នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ**
**លេខទូរស័ព្ទ ០២៣ ៩៩០ ១៩៦ / ០១២ ៥៦៧ ៨៤៨ / ០១៧ ៧០៧ ៧០៩**
**អ៊ីម៉ែល** nbccommunication@nbc.org.kh